**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធនធានទឹក និងឧតុនិយម**

លេខ ២៦១ សរណ ធទឧ

## សេចក្តីជូនដំណឹង
## ស្តីពី ស្ថានភាពកម្ពស់ទឹកទន្លេ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុ និងស្ថានភាពទឹកទន្លេមេគង្គរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ៖ ដោយសារឥទ្ធិពលរបស់ប្រព័ន្ធសម្ពាធទាប ដែលបាន និងកំពុងអូសកាត់ពីលើអាងទន្លេមេគង្គ ក្នុងប្រទេសមីយ៉ាន់ម៉ា ថៃ និងឡាវ បានបង្កឱ្យមានភ្លៀងធ្លាក់ និងជម្រុញឱ្យកម្ពស់ទឹកទន្លេមេគង្គកម្ពុជា ទន្លេបាសាក់ ទន្លេសាប និងទឹកក្នុងបឹងទន្លេសាប កើនឡើងជាបន្តបន្ទាប់ ។ យោងតាមការព្យាករ បរិមាណទឹកដែលមានស្រាប់ នឹងធ្វើឱ្យទឹកទន្លេទាំងអស់ក្នុងប្រទេសកម្ពុជា បន្តកើនឡើងសន្សឹមៗ ក្នុងកំឡុងពេលប្រមាណ ០១ សប្តាហ៍ ទៀត និងអាចធ្វើឱ្យតំបន់ទំនាបមួយចំនួនដែលស្ថិតនៅអមសងខាងដងទន្លេមេគង្គលើ ( ក្នុងខេត្តស្ទឹងត្រែង ក្រចេះ និងខេត្តកំពង់ចាម ) ចាប់ផ្តើមលិចជាបន្តបន្ទាប់ ។ ការលិចនេះអាចនឹងធ្វើឱ្យមានការប៉ះពាល់ដល់ដំណាំកសិកម្មរបស់ប្រជាពលរដ្ឋនៅតំបន់ទាំងនោះផងដែរ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអាជ្ញាធរដែនដី និងប្រជាពលរដ្ឋ ដែលរស់នៅតាមដងទន្លេ ពិសេសទន្លេមេគង្គកម្ពុជា ក្នុងខេត្តស្ទឹងត្រែង ក្រចេះ និងខេត្តកំពង់ចាម មានវិធានការប្រមូលកសិផលឱ្យទាន់ពេលវេលា និងត្រូវបង្កើននូវការយកចិត្តទុកដាក់ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០១៥*

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh